៨០- សត្វសឹងសាហាវកាចក្រៃ យង់យល់ក្សត្រថ្លៃ ពុំអាចហ៊ានកាត់ភោក្ដា ។
ស្ដែងស្ដេចយល់យង់មច្ឆា និរនែសភយា ឥតត្លុកដល់ប៉ុនកេសី ។
ព្រះអង្គពុំគិតជីវី គិតតែប្អូនស្រី នូវបុត្របណ្ដូលពីរពង្ស ។
ស្ដេចខំហែលកាត់តម្រង់ ដូចដល់កំពុង ដែលដាក់នាងនាថជាយា ។
៨៥- ស្រេចស្ដេចឡើងទៅម្ដីម្នា មើលសព្វទិសា រត់រកសព្វស្ថានពុំយល់ ។

បទព្រហ្មគីតិ

១២៥-កាលនោះពោធិសត្វ បុរសរ័ត្នវិសេសសល់
ស្ដេចរកនាងនិម៌ល សព្វតំបន់ព្រៃព្រឹក្សា ។
ពុំយល់ឡើយព្រះចៅ ដង្ហោយហៅវរជាយា
ពុំឮសព្ទភាសា ស្ដេចរឹងទល់វែងទុក្ខធ្ងន់ ។
ឱបាបអ្វីនាគ្រា វែងត្រូវជាទុក្ខពេកពន់
ប្រាសបុត្របណ្ដូលគន់ ហើយប្រាសទាំងវរជាយា ។
ម្ល៉េះហើយសមនឹងក្ស័យ សូន្យនាថ្ងៃនេះឯងណា
ផ្ដិលផ្ដាច់ស្រេចជន្មា នឹងរស់នៅវេងកម្មអ្វី ។
ឱអង្គអញអភ័ព្វ សូវអេញស្លាប់ក្នុងជលធី
សង្វាតហែលឃ្លាតខ្លី មករកប្អូនមាសសង្សារ ។
មិនដឹងជាប្អូនស្រី ប្រាសទូរទីទៅឥតការ
ទ្រងបងជាំជាំដាល ព្រួតនូវទុក្ខពុំត្រាស្បើយ ។
១៣០ ព្រះអង្គសោយសោកា គត់ឱពជាំអស់ហើយ
ប្រះប្រាណព្រះកេសកើយ លើក្រឡាមហាប្រថពី ។



សែនសោយសោកសន្ទប់ ញ័រចំប្រប់អស់ឥន្ទ្រិយ
លុះភ្ញាក់ព្រះស្មារតី ថ្លែងទំនួញអស់នេះថា ។
ឱប្អូនមាសកំសត់ សង្វាតរត់ចាកសីមា
តាមបងពុំឃ្លាតឃ្លា ទាំងរាត្រីត្រាច់តាមដាន ។
បីបុត្រទាំងពីរពេញ ចរចាកចេញពុំសម្រាន្ត
ហេតុតែនាងកល្យាណ នាងចិត្តបានពន់ពេកក្លាត់ ។
ឥឡូវនេះមកប្រាស ព្រាត់និរាសទាំងបីបាត់
ប្រាសប្អូនប្រាសកូនរ័ត្ន ទៅទីទៃព្រាត់ឃ្លាតឃ្លា ។
១៣៥ឱបងវែងឆ្ងាយឆ្ងល់ រិះពុំយល់ក្នុងចិន្ដា
ក្រែងព្រានត្រាច់ព្រឹក្សា អកជួបជួននឹងប្អូនស្រី ។
វាចាប់យកប្អូនទៅ ទាល់លំនៅក្នុងបុរី
ហើយយករាជទេវី ជាភរិយារួមស្នេហ៍ស្នង ។
ឬមួយសត្វម្រឹគា ក្នុងព្រឹក្សាទ្រុស្ដទ្រើសឃ្នង
វាពាំនាំទៅផ្គង យកប្អូនទៅបរិភោក្ដា ។
ឬមួយប្អូនព្រលឹង នាងទន្ទឹងបងខ្លោចផ្សា
យល់យូរពន់វេលា កាលហើយចាកចរចេញទៅ ។
ក្រែងប្អូនត្រាច់ព្រឹក្សា រស់ទេវតាឃកប្អូនពៅ
លាក់ទុកក្នុងព្រៃជ្រៅ ឲ្យតែបងវងទុក្ខធ្ងន់ ។
១៤០ ឱប្អូនមាសប្រសើរ បងត្រាច់ដើររកគយគន់
សព្វព្រៃសព្វតំបន់ បងពុំយល់មាសពុំងា ។

ស្តេចទួញហើយទួញទៀត រំងចង្អៀតអស់ឱព
សាច់ស្វគផ្កាយផ្សព្វផ្កា អនអាក់អួលរំជួលក្តៅ ។
រហេតុឈឺព្រះប្អូនស្រី ប្រាសទៅទីទៃលំនៅ
ស្តេចសោយសោកហើយហៅ រត់រកសព្វព្រៃព្រឹក្សា ។
នឿយណាស់ឈប់សម្រាន្ត នៅក្រោមឋានដែលនេះណា
វែងសោយសោកច្រើនគ្រា តែងទុក្ខធ្ងន់ពន់ពេកក្តាត់ ។
ព្រះនេត្រាជោរផល ស្រក់ដូចដល់ឱរាក្ត
ទៀងទួញក្នុងព្រៃស្ងាត់ ទួញលន្លង់លន្លោចលន់ ។
១៤៩ ឱប្អូនមាសថ្លើមថ្លៃ បងស្រមៃឃើញគយគន់
យល់តែដានតំបន់ នៅនេះតើប្អូនទៅណា ។
អាស្ងរមេមាសថ្លាំ នោះបងចាំពាក្យវាចា
ឲ្យបងឆាប់លីលា នានាំបុត្រទាំងពីរពង្ស ។
ឥឡូវនេះបុត្រចាត់ នាងប្អូនរ័ត្នសឹងបោះបង់
ឱបងតែឯកអង្គ ម្រាងនឹងបានរស់ជន្មា ។
ឱបាបបងកាលជាតិ នេះឲ្យឃ្លាតពីប្អូនភ្ញា
ឃ្លាតទាំងពជបុត្រា ហេតុអំពើបាបផ្តិលផ្តាច់ ។
ស្តេចគិតគុណសីលា ចាំរក្សាពុំដែលដាច់
កម្រង់ស្មារតីស្រេច លើកកំបង់វរវន្ទា ។
១៥០ បង្គំទេពទិសទស ស្ងត់សោឡសព្រះព្រហ្មា
បពិត្រអស់ទេព្តា សូមអ្នកជួយយកជីវិត ។



ឲ្យខ្ញុំទាំងប្អូនបាន មូលមួយឋានរួមស្នេហ៍ស្និទ្ធ
អញខ្ញុំសូមសម្រឹទ្ធិ ឲ្យបរិបូណ៌ដូចប្រាថ្នា
សូមអស់ទេពទាំងនោះ ជួយបណ្តោះទុក្ខនាគ្រា
នោះសូមអស់ទេព្តា ជួយចម្រើនឲ្យក្សេមក្សាន្ត ។
បពិត្រព្រះឥន្ទ្រា ឋិតនៅនាត្រៃត្រឹង្សឋាន
សូមអ្នកបើកទិព្វញាណ ឈ្វេងយល់ទុក្ខខ្ញុំពេកក្តាត់ ។
សូមអ្នកមានមេត្តា ទ្រង់ករុណាអាសូរសត្វ
កុំឲ្យប្រាសព្រាយព្រាត់ សូមឲ្យជួបមូលមួយឋាន ។
១៥៩ ព្រះពង្សពោធិសត្វ បុរសរ័ត្នស្តេចប្រណិធាន
ស្រេចស្រាប់សោកប្រះប្រាណ ដួលសន្លប់បាត់ស្មារតី ។
ព្រះអង្គវែងទុក្ខទល់ ហេតុអំពល់អំពើព្រៀវ
កាលស្តេចយកបក្សី សត្វសេកសោមឲ្យបុត្រា ។
ទាំងពីរយកមកលេង គិតពុំក្រែងព្បៀររវេព
ហើយបោចរោមសារិកា បីទងទើបឈាមប្រាលផ្លោ ។
យកកូនពីសម្បុក មេជាទុកពេកក្តាត់ក្តា
ហើយយកទៅទុកនៅ ដែលដូចដើមពីមុននៃ ។
ហេតុកម្មនេះឯងណា ពុំឃ្លាតឃ្លាទាន់លោកតិយ
ឲ្យស្តេចប្រាសទៅទី- ទៃលំនៅបុត្រភរិយា ។
១៦០ កម្មកើតមិនតែម្តង ឡើយតែងរងព្បៀររវេព
ប្រាំរយជាតិគណនា ទើបនឹងរួចពីទុក្ខភ័យ ។

កាលនោះពោធិសត្វ បុរសវ័ន្តវិសេសថ្លៃ
សន្ធប់យូរលង់ក្រៃ លើក្រឡាមហាប្រឹថពី ។
ទើបស្តេចប្រែព្រះអង្គ ទំតម្រង់ព្រះស្មារតី
ដោះឡើងរកទេវី ពុំយល់ឡើយស្តេចសោកា ។
វែងកើតទុក្ខទៀតថ្មី ក្បិតឈឺស្រីសង្សារ
ជោរផលនេត្រធារ ពិលាបលន់ពន់ប្រមាណ ។
ហើយស្តេចបន្ទោរបង់ ទើបព្រះអង្គទ្រង់ញេយ្យញាណ
សង្វាតរំពឹងធ្យាន យល់សង្សារសឹងស្រោលស្រែ ។
១៦៥ ពុំគួរនឹងត្រអាល វាបណ្តាលលល្ងង់ទេ
គួរប្រាសលះកុំស្នេ- ហានុវត្តិវង្គសង្សារ ។
ព្រះពុទ្ធពីបុរាណ ទ្រង់ទូន្មានសព្វប្រការ
ព្រះធម៌ជ្រៅពិស្តារ ទេសនាទុកជាសណ្តាប់ ។
កុំឲ្យសត្វទាំងឡាយ សែនសោកស្តាយក្តីពុំគាប់
សុខហើយប្រែក្រឡាប់ កើតជាទុក្ខទោសភយា ។
ហេតុនោះព្រះអង្គផ្ទៀង យល់ពុំទៀងគិតអនា-
គតគួរកុក្កា(១) ជាត្រើយត្រាណទីពំនាក់ ។
ព្រះពោធិចក្រិន ចមនរិន្ទធិរាជរ័ក
ផ្ទៀងយល់ធម៌ផ្ទៀងជាក់ ហើយស្រាកស្រាន្តទុក្ខសោកា ។
១៧០- ទើបស្តេចដើរយាសយាង ទៅតាមនាងវរជាយា
ត្រាច់ក្នុងព្រៃព្រឹក្សា ស្វន្សជ្រងំពន់ពេកក្រាត់ ។

———
១- លេៈកុត្តា ។



ស្តេចដើរត្រាច់ខ្វីឃ្វាត ខំសង្វាតរុកពានកាត់
ដោយដងព្រៃស្រងាត់ ពុំដឹងដែនដានមាគ៌ា ។
នឿយណាស់មហាក្សត្រ ក្សាន្ត ឈប់សម្រាន្តរើសផលា
ទុំជ្រុះដោយពសុធា ស្តេចបរិភោគផលពិសី ។
ពិសាផ្អែមដូចឃ្មុំ ផលទុំ ៗ ជោរនៅដី
សព្វសត្វចុះចឹកស៊ី ស្រែកនូវសព្ទសូរសោសម ។
គ្រលេងគ្រលោងហើរ ទន់ទាបទើរទន្ទឹមទុំ
ឈ្មោលញីហើរយាសយំ ស្រែកនូវសព្ទសូរក្រអៅ ។
១៧៥ លលកលលេលេង ហើរទទ្វេងទន្ទឹមនៅ
គេងកងអង្គត់ខ្មៅ ហិចហើរទៅទំបន្ទាប់ ។
ចចាតចចើងចេញ មើរឃ្មាតខ្វាញ់ចរចុះចាប់
វក្កាស្រែកនូវសព្វ ហើយហើរទៅទំទន្លា ។
ទទាទទះស្លាប ហើរទន់ទាបទំលតា
ចឹកចាប់ភ័ស្តុភោក្កា ទំលាក់រុះរាយដោយដី ។
ពក្លាតពក្លាមទៅ ហើរសំដៅរកចំណី
ទំទឹមទាំងឈ្មោលញី ប្រចឹកចាប់ដណ្តើមផល ។
សេកសៀមសៀវស្វចឹក កល្បព្រឹក្សបរិភោគស្គាល់
ស្ទាំងស្ទាក់ស្ទុះដេញដល់ ចឹកដណ្តើមភ័ស្តុផលា ។
១៨ សសេះសសៀវផ្ទាប់ ចុះចូលចាប់ដើមវក្កា
ទំទឹមទាំងគូភា លោតលោតលើព្រឹក្សាសាយ ។

ចេកទេសចេកទុំទំ ទៀបទ្រនំសេងសប្បាយ
ទុងទោមទំរលាយ ទាំងទៀវទោចលន្ទោចព្រៃ ។
ស្តែងស្តេចឮសព្ទសត្វ យំស្រងាត់ក្នុងព្រឹក្សព្រៃ
សែនសោយសោកអាល័យ អាឡោះលន់ពន់ពេកក្តាត់ ។
ស្តេចថាឱសត្វផង វាស្នេហ៍ស្នងប្រតិព័ទ្ធ
តែអញប្រាសព្រាយព្រាត់ ចាកចំរែងអសារសល់ ។

## បទភុជង្គលីលា

ពណ៌នាព្រឹក្សាដោយផ្តល់ វុះរោយរាយផល អនេកត្រៀបត្រា ។
ព្រសព្រីងបុស្សបេងទន្លា ទន្លាប់កេកា សំរោងសំរង ។
ស្នែស្នាច់លាយលេចអង្រ្គង ត្រៀបត្រាចភ្លូភ្លង ច្រេសជ្រយក្រស្នា ។
មង្ឃុតល្មុតសេដា ស្រល់ស្រូលផាំឆា ត្រឡាត់ត្រឡក ។
សម្ពង្រនូវផ្លូក ត្រៀកត្រាចប៉ប្រេក ខ្វាវខ្វិតខ្ទុះខ្ទារ ។
ស្វាតស្វាយក្រូចក្រាបរកា ពរពេលពពារ កប្បាសក្រចៅ ។
ផ្តកផ្តៀតកង្រៃកតាត្រៅ ចាកចេកព្នលព្នៅ ផ្តីក្បាំងក្រកោះ ។
ត្រើលត្រង់លពង់លំពស់ រលួយរលោះ រលាយរលា ។
ផ្កាវផ្កុងផ្កាផ្គង់ពុទ្រា ត្រួយត្រល់ត្រៀលស្វា ទ្រមូងទ្រមួច ។
មង្ឃុតល្មុតពោនពួច បុស្សបេងសង្ឃួច សង្ឃ័រសង្ឃា ។
ក្រឡាញ់អង្កាញ់ចន្ទន៍ចារ សៀងព្រាសំព័រ ស្តីស្តង់ស្តីស្តៅ ។
ពោធិ៍ពៃច្រេសជ្រៃត្រៀបត្រៅ បុស្សបេងបង្គៅ ក្រវាញក្រវាន់ ។
គរគុយរុយសណ្តាន់ លំពស់លំពាន់ ដកពដកពាយ ។



អំពៅក្រចៅលេចណាយ ល្បៀបលោតវល្លិវាយ វល្លិវែកទាស់ទាល ។
សុក្រំពាំងភ្នំសត្វា កោដ្ឋកែវក្រួចឆ្មារ កន្ទោកន្ទែ ។
ក្រសាំងមានទាំងលាំងដៃ ភ្លូភ្លងឃ្លេឃ្លៃ រំដួញរំដេញ ។
ក្រិន្នាពុទ្រាផ្កាផ្ទេញ- ត្រីត្រាចប្រផេញ ខ្ទឹងក្ទម្ពសុរភី ។
មៀងជាងមាក់ប្រាងកាកី មាក់ដោកស្រឡី បង្គៅបង្គារ ។
ច្រេសជ្រួយប្រមួយខ្វិតខ្វារ ក្តាតក្តួចវល្លិ៍យាវ វល្លិប្រេងឆ្លាល់មាន់ ។
កាកេសចេកទេសទៀបចន្ទន៍ ក្រស្នាវល្លិវ័ណ្ណ ស្រគំស្រគាល ។
សំកុងព្រះក្រុងព្រេចព្រាល ទ្រយឹងឈើទាល ល្មើល្មុតសេដា ។
ព្រៃស្រោងរំលោងបពូតា សឹងជ្រំផលា ទុំរុះពាយរោយ ។
ព្រះមហាក្សត្រាដើរដោយ ហាត់ហោងជ្រុងជ្រោយ លង្វែកសិលា ។
ដងអុរចង្ហុរគង្គា ជ្រោះជ្រៅរងថ្លា ស្រណុកសប្បាយ ។
ស្រះស្រង់កំពុងទូលាយ ភ្ញីផងទាំងឡាយ ជាសដុះត្រៀបត្រា ។
មហាហង្គប្រយង្គចម្បាំ ចំប៉ីក្តាំងងា កាកែសន្ធនស្រី ។
លន្តែមរង្គមាលតី រំចេកសុរភី ស្រម្បិតផ្កាច្បារ ។
ដុះដិតប្រកិតមាត៌ា រោយរុះបុប្ផា ពិដោរត្រឡប់ ។
ធុំហួងអស់អង្គឈួយឈ្ងប់ ល្វេងល្វើយសាយសព្វ ក្នុងព្រៃព្រឹក្សា ។
ស្តេចគិតអាណិតសង្សារ សែនសោយសោកា ទួញទៅប្អូនស្រី ។
ឱប្អូនខ្លឹមខ្លួនពិសី បងយល់អស់ក្តី រន្ធាលប្រាលឆ្មៅ ។
បងមហាខ្លោចផ្សារក្តួលក្តៅ ទ្រូងត្រួតក្រំនៅ តែងគិតប្អូនភ្ងា ។
ច្នះចៅនាងនៅនេះណា បងនឹងបេះផ្កា ឲ្យនាងជ្ជូតលេង ។
ផ្កាប្រាលរន្ធាលរោយឯង ដើមដុះពីព្រេង ស្រស់ស្រិចខៀវខ្ចី ។

លំពង់រហង់ទ្រង់ក្អី ផលាពិសី ពិសេសពិសាល ។
ក្រពុំខ្លះទុំស្រគាល ខ្លះទើបស្របាល ក្តិបលេចពីទង ។
ក្សត្រាលីលាដោយដង ថ្នាក់ថ្នល់ជ្រលង ទតអស់បុប្ផា ។
ដើរត្រាច់លុះលេចអធ្វា ដល់ឆ្នេរគង្គា វាលវែងបូបឹង ។
សព្វសត្វច្រើនក្តាក់ទ្រហឹង ដំរីស្រប់ស្រឹង គោត្រក្លោងត្រៀបត្រា ។
ខ្លះស្រប់ខ្លះឈប់រេរា ខ្លះផល់រអា រួសរត់ចេញក្រៅ ។
ខ្លះអរខ្លះឈរចាប់ស្មៅ ខ្លះស្រប់និត្យទៅ ភាល់ញីសប្បាយ ។
រមាំងខ្ទឹងខ្លាំងប្រើសទ្រាយ ទន្សោងទន្សាយ គោគោមហឹង្សា ។
ផ្តៃព្រៃក្រាស់ក្រៃត្រៀបត្រា ចចកស្វានស្វា ឈ្លូសស្មាន់ពពៃ ។
ឆ្មាបាប្រមាប្រឹងប្រែ ងើយងរកផ្លែ កែកាងបាញ់បោះ ។
មានចៀមរេរាកាល់កោះ ញីញងបារោះ បណ្តើរហ្វូងហ្វាយ ។
អ្វូតអរចេញចរសប្បាយ រួសរត់រពាយ ស៊ីស្មៅយាប្លង ។
រមាសលលាសផ្ទៀងផ្ទង រកអាហារផង ស៊ីតែបន្លា ។
ស្រាក់ស្រងដោយផងព្រឹក្សា រូបរាងមមា បម្ញាតញីក ។
ពព្លូកហ្វូងជ្រកគគីក មេត្រោសពន្លឹក ដើរដោយជ្រលង ។
នាំកូនពពូនត្រសង ស្រែកសព្ទរំពង ដាលដេញខាំគ្នា ។
អស់ម្រឹគគគីកពើបពារ ចរផ្លូវក្សត្រា រួសរត់ប្រញាយ ។
មានខ្លាលីលាជជាយ លោតលេងសប្បាយ ដេញចាប់អស់ម្រឹគ ។
សត្វផងឃ្មើសឃ្មងគគីក ខ្លះចុះផឹកទឹក ខ្លះចាំឈប់ឈរ ។
ខ្លះដេកខ្លះស្រែកងើយងរ ខ្លះខ្លាចចេញចរ ឃ្លោឃ្លាតចាកឆ្ងាយ ។



ក្សត្រាថ្ងៃថ្លាពណ្ណរាយ យល់សត្វទាំងឡាយ យំរកគ្នា ។
ព្រះអង្គស្តេចគង់សោកា គិតដល់ជាយា អយ់អគ្គមហេសី ។
ឱសត្វសឹងព្រាត់ឈ្មោលញី ដូចមេប្អូនស្រី ប្រែប្រាសពីបង ។
ប្អូនអើយម្ល៉េះហើយនឹងរង ទល់ទុក្ខកន្លង ផ្សាខ្លោចឱរា ។
ឱពៅនាងនៅស្ថានណា តែឯងកំព្រា ដូចសត្វព្រាត់គូ ។
បងមករួសរកឥឡូវ ពុំដឹងដែនផ្លូវ ដើរដូចយាត្រា ។
ត្រមោចលន្លោចកំព្រា គតមានអ្នកណា កំដរពីរផង ។
ដំណើរស្តេចដើរវិលវង់ អស់វាលនោះហោង ទៀបទៅសីមា ។
នគរបវរថ្លៃថ្លា ហៅតក្កសីលា បុរីរម្យរាជ ។
យល់ថ្មមួយល្អពិញាច ចិញ្ចែងត្រដាច ត្រដូចផាលដុះ ។
ល្អល្អះត្រចះឆ្លាក់ឆ្លុះ រស្មីភ្លឺប្រុះ ដូចកែវស្សុរ្យកាន្ត ។
ព្រះបាទនរនាថថ្កើងថ្កាន ចូលចតសម្រាន្ត លើថ្មសិលា ។

**បទភាគគតិ**

៧៣- រីនឹងស្រដី និទានពិតពី មែនមានក្សត្រា
ទ្រើសទ្រង់អំណាច គ្រងរាជ្យនគរា ក្រុងតក្កសិលា
ធារធំថ្កើងថ្កាន ។
អង្វេងយូរលង់ លុះព្រឹទ្ធព្រះអង្គ ព្យាធិមែនមាន
សោយរំលាល័យ ក្សត្រថ្លៃប្រធាន រាស្ត្រទាសសព្វស្ថាន
ទល់ទុក្ខក្តាត់ក្តៅ ។
៧៥-ស្តេចឥតបុត្រា នឹងគ្រងរាជ្យា តំណារៀងទៅ
មន្ទីរប្រាសាទ ស្ងាងស្ងាតសន្ធៅ គ្មានស្តេចគង់នៅ
សូន្យសោះស្ងាត់ឈឹង ។

ព្រះស្នំស្រីផ្កា នារីបរិពារ ស៊ីងសោកទ្រហឹង
សង្រេងសង្រែ សព្វថ្ងៃអឺអឹង ទល់ទុក្ខសន្ធឹង
ក្រៀមក្រំកក្រា ។
អស់មុខមន្ត្រី សេនាបតី ព្រះញាតិវង្សា
អស់រាស្ត្រព្រាហ្មណ៍ព្រឹទ្ធ ប្រាជ្ញបណ្ឌិតា មូលមកសាលា
ជំនុំពុំដាច់ ។
ហោរាបុកបាន រកឫក្សមួយស្ថាន ពេលាសម្រេច
មៀងមើលជតា លក្ខណាស្រុកស្រេច គន់គូរបុកផ្ចាច់
ផ្ទៀងផ្ទេរតម្រា ។
ហោរគូរសព្វសាយ ហើយហោរទៀងទាយ ដោយក្បួនសាស្ត្រា
យោគយាមយាយី ពារពីធីតា ថាមានក្សត្រា
ចូលថ្កានបុរី ។
៨០- ថ្មីរទេសលីលា មែនមានចេស្តា លើសលែងលោកិយ
ត្រកាលត្រកូល អម្បូរជាតិ នឹងគ្រងបុរី
បុរាណរដ្ឋ ។
ចូរអស់មន្ត្រី រើសរកហត្ថី សម្រាប់រាជា
ចងគ្រឿងប្រដាប់ ស្រេចស្រាប់សង្ហា ផ្សងបារមិតា
ហើយលែងទៅហោង ។
ស្តាប់ហោរស្រដី រំពេចឃ្មាតខ្មី រូសរៀបអឹងកង
ប្រដាប់ដំរី គ្រឿងថ្មីសឹងចង គ្រែរាជយានផង
រាជរថពាជី ។



ក្លៀងក្លស់ច្រើនជាន់ ឆាម៉រសែនត្វូន បែមន៍មណី
អភិរម្យរ័ត្ន ព័ទ្ធវិជនី សម្រាប់បុរី
បុរាណរាជា ។
គ្រែស័ង្ខកេរ៍ សេពសបខ្ចុយប៉ុ ពិណពាទ្យស្គរជ្វា
ប្រដាប់គ្រប់ក្លែង ស័ក្តិសែងភាព អស់ទាំងសីមា
រូសរៀបស្រេចស្រាប់ ។
៨៥ -ធុំមុខព្រះលាន ពលផងមីរមាន ដេរដាសតាន់តាប់
រៀបរង់ពេលា ហោរាបង្គាប់ គន់គូរស្រេចស្រាប់
យោគយាមយាត្រា ។
ទើបមុខមន្ត្រី ព្រាហ្មណ៍ព្រឹទ្ធករ៍ រាជវង្សសេនា
ប្រដាប់បុស្សរថ ពិចិត្រថ្លៃថ្លា ប្តឹងអស់ទេវតា
ប្រណិធានផ្សង ។
បើអ្នកឯណា មែនមានចេស្តា នឹងបានគ្រប់គ្រង
រដ្ឋរាជធានី បុរីនេះហោង សូមទេវតាផង
នានាំទៅខ្មី ។
សូមឲ្យគជេន្ទ្រ គជសារនរេន្ទ្រ បីក្សត្រធិបតី
លើកឡើងដាក់ដល់ មណ្ឌលសិរសី នាំមកបុរី
រដ្ឋរាជសីមា ។
ផ្សងស្រេចពុំលង់ បុស្សរថវរម- ង្គលគាប់សោភា
ផញ្ចូចទ្រហឹង ប្រែប្រឹងហត្ថា លុតលើកបាទា
ទៀងទើបចេញចរ ។

៩០ -គម្រង់ទិសទី ស្ថានដែលពោធិ- សត្វស្ថិតបវរ
ផ្ដុំលើសិលា ក្រៅទ្វារនគរ ព្រះបាទភូធរ
ឯកឯងកំព្រា ។

គជសារដើរដល់ មៀងមើលទោយល់ ព្រះពង្សពុទ្ធា
បាទបត់ផង្សផ្ទួញ កង្កាញហត្ថា ទ្រោមទ្រុឌសិរសា
ផញ្ចួចឥតអាក់ ។

អស់មុខមន្ត្រី យង់យល់ហត្ថី ទ្រោមទ្រុឌហើយហាក់
គោរពព្រះបារមី ក្សត្រឥស្សរស័ក្តិ អស់ទាំងនាងអ្នក
យល់ជាអស្ចារ្យ ។

ស្រែកហោបីដង ឮលាន់រំពង កក្រើកទូទ័រ
បើអ្នកអបល័ក្ខណ៍ ហីនស័ក្តិសម្មា សមតឹកតិយញ្ញ័រ
រួសរត់ចេញក្រៅ ។

ឯក្សត្រវរវង្ស សមស័ក្តិចមពង្ស ស្ដេចមៀងមើលទៅ
យល់អស់សេនា បរិពារនិត្យនៅ ក្សត្រក្សាន្តចមចៅ
ជ្រាបក្នុងចិន្តា ។

៩៥- ថាអស់នេះឯង សម្រាប់ពីព្រេង អង្គអញឯងណា
ព្រះមហាក្សត្រក្សាន្ត ពុំមានភ័យា ពិតពុំនាំពា
ដឹងដោយយោបល់ ។

ទើបអស់មន្ត្រី ព្រាហ្មណ៍ព្រឹទ្ធករ៍ ចតុរង្គពោហ៍ពល
ក្រាបថ្វាយបង្គំ ជួបជុំចូលដល់ យល់ក្សត្រនិម៌ល
ទ្រង់នោមឆាយា ។



កាលនោះព្រាហ្មណ៍ព្រឹទ្ធ ភារចូលទៅជិត យល់ស្នាមបាទា
មានទ្វីបទាំងបួន ស័ក្តិសួនលក្ខណា លើសលែងលោកា
រកផ្ទឹមពុំបាន ។

ទើបព្រាហ្មណ៍ឱនអង្គ លុតលើកកំបង់ បង្គំក្សត្រក្សាន្ត
ទៀងទូលអំពី បុរីពជស្ថាន ឥតក្សត្រប្រធាន
គ្រប់គ្រងវេណី ។

នគរនេះណា ឈ្មោះតក្កសិលា បុរាណបុរី
ឥឡូវសុន្យស្ងាត់ រាស្ត្ររដ្ឋមន្ត្រី ព្រាហ្មណ៍ព្រឹទ្ធករ៍
ឥតឯអាស្រ័យ ។

១០០ ស្ដេចសោយរំលា- ល័យលុះផព ព្រះជន្មក្សត្រថ្លៃ
បុរីសូន្យស្ងាត់ រាស្ត្ររដ្ឋប្រល័យ ប្រឡងអស់ឮ
ពិភពពជរម្យ ។

ពោធិវង្គល ស្ដេចស្ដាប់ទំនូល ព្រាហ្មណ៍ព្រឹទ្ធបង្គំ
ព្រមព្រះហឫទ័យ ក្សត្រថ្លៃឧត្តម ព្រះអង្គពិតពុំ
សន្និះសង្កា ។

ទើបព្រាហ្មណ៍បុរោហិត ភារចូលទៅជិត ថ្វាយព្រះគង្គា
ស្ទូត្រសែកស្លូតី វុឌ្ឍីជយា ស្រចស្រង់ព្រះមហា-
បុរសរត្នថ្លៃ ។

ស្រង់ស្រេចពុំលង់ មុខមន្ត្រីវង្ស ថ្វាយគ្រឿងទិព្វថ្លៃ
ព្រះពស្ត្រទិព្វទេស ពិសេសល្អក្រៃ ភូសាមាសម័យ
គ្រឿងផ្ដេកអស់អង្គ ។

ថ្វាយព្រះមកុដ មាលមាសបរិសុទ្ធ កែមកែវយល់យង់
ដាំពេជ្រប្រកិត ពាយរ័ត្នបញ្ចង់ ក្សត្រក្សាន្តវរវង្ស
ថ្កើងព្រះចេស្តា ។

១០៥ ភ្លេងផងច្រើនក្កាត់ បម្រើមហាក្សត្រ ក្រាស់ក្រៃត្រៀបត្រា
ស្រឡៃពាទ្យគង ស្គរធំស្គរដារ ទាំងស្គរហេងហ្វា
សេពសមខ្លួយប៉ី ។

ស្រែកពេទ៏បីផង ឮលាន់រំពង កក្រើកប្រឹថពី
ទើបអស់សេនា យោធាមន្ត្រី អញ្ជើញស្តេចលី
លាថ្កានព្រះនគរ ។

ទើបក្សត្រវរវង្ស ស្តេចឡើងទៅគង់ មុស្សរថបវរ
មង្គលហត្ថី ក្សត្រថ្លៃចេញចរ ដំណើរង៉ើយង៉
សន្សឹមយាត្រា ។

ព្រះពោធិជាតិ គួរគង់ប្រាសាទ ប្រសើរថ្លៃថ្លា
កញ្ចក់រំលេច ស្រស់ស្រេចសោភា មាលមាសសុវណ្ណា
ដាលដាំមណី ។

កាលនោះអមាត្យ ហែក្សត្រភូវនាដ ចូលទៅដល់ទី
ទាំងអស់ព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវី សែកសូត្រស្លូតី
សាចបាចគង្គា ។

១២០ ចម្រើនសុខំ អាយុវណ្ណំ វុឌ្ឍីចេស្តា
ចម្រើនសួស្តី ជោគជ័យក្សត្រា ឲ្យមានជន្មា
យឺនយូរយសស័ក្តិ ។



បុស្សរថពុំចូល ទ្វារទិសឯបូព៌ ហើយវិលប្រទ័-
ក្សិណបានបីជុំ ហើយផ្លុំត្រែប្រាក់ ពេត្តីរល័ក្ខណ៍
សន្សឹមចូលថ្កាន ។

ក្នុងព្រះរាជវាំង ក្លឹងក្លស់បើកបាំង ស្តេចចុះគង់យាន
គ្រែទែនទិព្វមាស ដាំដាសសោភ័ណ កែមកែវកល្យាណ
ព្រោងព្រាយរស្មី ។

ព្រះមហាក្សត្រក្សាន្ត ទតអស់ពិមាន ប្រាសាទសោភី
ប្រាំពីររូតរ័តន៍ បោសបិទសុវណ្ណី ប្រាសប្រាលរស្មី
កញ្ចក់ចាំងថែង ។

មុខព្រហ្មប្រសព្វ គូរជាមណ្ឌប ផ្សាជំរូត្រឡែង-
កែងកបស្រួចស្រស់ កំពស់កំពែង កំពូលស័ក្តិសែង
ពាល់រូបរចនា ។

១២៥ ព្រះអង្គសីហនាទ ឡើងលើប្រាសាទ ចូលក្នុងក្រឡា
កម្រាលពេងរ័តន៍ ពិចិត្រសោភា ព្រះស្នំត្រៀបត្រា
គង់គាល់ណាស់ណាន់ ។

ខ្លះកាន់ព្រះពស្ត្រ ព្រះសិទ្ធរស មាលាសុវណ្ណ
កាន់ពានព្រះស្រី មណីសោភ័ណ នាងខ្លះករកាន់
ព្រះវំផនី ។

ខ្លះកាន់ពពិល មាសម័យស្រស់ស្រិល ស្រីស្រេចសោភី
កាន់គ្រឿងសុគន្ធ ទិព្វគន់ពិសី នាងខ្លះកាន់ភ្លី
កម្រងមាលា ។

នាងខ្លះស្អាងអង្គ    កាន់ព្រះទម្រង់    សុព័ណ៌ចាទា
ខ្លះកាន់ព្រះឆាយ    កែក្រាយយាត្រា    នាងខ្លះចរចា
    សើចសមមានស្រី(១)    ។

នាងខ្លះយោងយោស    កាន់ផ្ទិតក្រជាស    ញញឹមប្រិមប្រិយ
ផ្សៀងផ្អងមើលគ្នា    សើចសារស្រដី    នាងខ្លះស្រស់ស្រី
    ស្រឡះអង្គា    ។

១៣០ សឹងពេញក្រមុំ    រូបរាងស័ក្តិសម    ផង់ផូរភក្ត្រា
ផរជាយផរផ្ទូរ    មុខគួរស្នេហា    ដណ្ដប់កាសាវ៍
    ជម្ពូទេសទុំ    ។

ទាងខ្លះមុខឈ្នង    ដណ្ដប់បៃតង    រូបរាងឧត្ដម
លាបប្រេងផាត់ម្សៅ    ល្អញល្អៅស័ក្តិសម    ដោះដុចបទុម
    មាសមានលក្ខណា    ។

នាងខ្លះមុខមូល    ផាត់ម្សៅត្រសុល    បំប្រិមផិតស្វា
ដណ្ដប់ស្បៃស្វាយ    ផុសក្លាយជាផ្កា    ទន់ភ្លន់អង្គា
    ស្រៀបស្រស់ល្មមល្អៃ    ។

ស្រីខ្លះរាងវៀវ    សម្បុរសខៀវ    ខឹមខាត់បំប្រែ
បំប្រិមស្រៀបស្រស់    សោឡសឆ្នាំនៃ    ដើរដណ្ដប់ស្បៃ
    សេតសមរូបា    ។

នាងខ្លះមុខម៉ដ្ឋ    សាច់សស្រគត់    ផង់ផូរភក្ត្រា
ដណ្ដប់ស្បៃខ្មៅ    ទើបទៅនាំគ្នា    គង់គាល់ក្សត្រា
    ជាជួរវៀងរាយ    ។

---
១ មានសិរីសួស្ដី ។



១៣៨ អស់អង្គសេនា    គាត់តែងយោធា    រួសរៀបខ្វល់ខ្វាយ
ករីព្រាហ្មណ៍ព្រឹទ្ធ    បណ្ឌិតប្រាជ្ញប្រាយ    ទូលក្សត្រពណ្ណរាយ
    ពិរាជចេស្ដា    ។

បពិត្រព្រះអង្គ    ពិសេសទ្រើសទ្រង់    បុណ្យបារមិតា
ស្ដែងស្ដេចជាច្បង    កន្លងលោកា    សូមព្រះរាជា
    សេពសោយរាជ្យគ្រង ។

មាត្យអុខមន្ត្រី    ព្រាហ្មណ៍ព្រឹទ្ធករី    ប្រជារាស្ត្រផង
ព្រះស្នំស្រីង្គារ    សោកាកន្លង    ថ្វាយក្សត្រច្បាស់ច្បង
    សម្រាប់រាជា    ។

ស្ដេចស្ដាប់ព្រាហ្មណ៍ទូល    ទើបក្សត្រឥសូរ    បើកបន្ទូលថា
ហៃរាជករី    មន្ត្រីសេនា    ព្រះញាតិវង្សា
    ត្រកូលក្សត្រថ្លៃ    ។

១៣៩ ថ្វីមិនលើកឡើង    តម្កល់តំកើង    តាងក្សត្រផ្សេងស្នងស័យ
សេពសោយសម្បត្តិ    ជាក្សត្រថ្លាថ្លៃ    រាស្ត្ររដ្ឋប្រស័យ
    រដ្ឋរាជសីមា    ។

១៤០ អង្គអញនេះហោង    ពិតពុំប៉ុនប៉ង    ចិត្តចងប្រាថ្នា
សោយរាជសម្បត្តិ    រម្យរដ្ឋនេះណា    អញព្រាត់ករុំយា
    នូវបុត្របង់បាត់    ។

ហៃអមាត្យអើយ    អញលាក់អ្វីឡើយ    អញឯងជាក្សត្រ
និត្យនៅបុរី    ទិសទីឆ្ងាយក្ដាត់    នាមនោះទៀងទាត់
    ចម្បាកនគរ    ។

បទុមអនុជា ទ្រើសទ្រុស្តមោហា រលីកពលរីករវ
បង្កើតជាសឹក ពន្លឹកខ្ទារខ្ទរ ទើបអញចេញចរ
នាំបុត្រភរិយា ។
អញពុំច្បាំងផង ប្រកួតប្រឡង នឹងអនុជា
រីពជសម្បត្តិ អញពុំប្រាថ្នា អញបង់សីមា
ត្រាច់ត្រង់ហិមពាន្ត ។
១៣០ សាងសីលព្រឹត្តព្រត អស់អញលំនុក ប្រយោជន៍ក្បៀមក្សាន្ត
ចៀសចាកវេរា អាត្មាឲ្យបាន ត្រាស់ត្រាច់ទ្រង់ញាណ
នាំសត្វសំខ្យា ។
១៤៩ ហេតុកម្មអញឯង ពៀរពិតពីព្រេង ជាតិមុននាយណា
តាមទាន់អង្គញ នៅព្រៃព្រឹក្សា ជួនយប់សន្ធ្យា
ងងឹតសូន្យឈឹង ។
ពុំយល់ទិសា វង្វេងមាគ៌ា ដើរដួចដល់ស្ទឹង
ទន្លេធំសល់ អំពល់ពាក់ពឹង រកអ្នកណានឹង
ចម្លងរួចបាន ។
អញហែលទាំងយប់ ខិតខំពុំឈប់ នាំនាងកល្យាណ
ទុកបុត្រពីរពង្ស ឲ្យរង់នៅខាន ចាំនៅត្រើយត្រាណ
ឆ្ពៀរឆ្ពរជលសា ។
លុះអញវិលមក រកបុត្រពន្លក ដែលនៅនាយណា
ពុំយល់សូន្យសោះ អញឆ្ពោះយាត្រា រកនាងប្អូនភ្ងា
សឹងបាត់ពុំយល់ ។



អញត្រាច់រុករាន ស្វះស្វែងដល់ស្ថាន សិលាមង្គល
រកពជបុត្រា ធិតាស្ងួតសល់ គ្រមោចទុក្ខល
ម្នាក់ឯងកំព្រា ។
១៩០ អង្គអញនេះនឹង តាមបុត្រព្រលឹង ទាំងពីរអង្គា
នូវអគ្គមហេសី ទៅថ្ងៃថ្លា ឲ្យជួបផងគ្នា
ដូចដែលប្រក្រតី ។
នោះបើអ្នកផង ចង់ឲ្យអញគ្រង រាជ្យប្រពៃណី
អញពុំប្រកែក អល់ឯកឡើយនៃ នេះមានតែក្តី
ទុក្ខតែងសោកា ។
អស់មុខមន្ត្រី ក្រាបវរន្ទីយ បង្គំក្សត្រា
បពិត្រព្រះអង្គ សូមទ្រង់មេត្តា អស់រាស្ត្រប្រជា
ទល់ទុក្ខក្តាត់ក្តៅ ។
បើឥតពីក្សត្រ នគរនេះស្ងាត់ ទាំងក្នុងទាំងក្រៅ
កើតកោលាហល កង្វល់សុបសៅ អន្តរធានទៅ
ទាំងរាជ្យសម្បត្តិ ។
ឯអស់ព្រះវង្ស ព្រះញាតិពូជពង្ស អម្បូរទៀងទាត់
សុទ្ធសឹងពុំមាន សន្តាននឹងក្សត្រ អសារបង់បាត់
បីបួនឆ្នាំហើយ ។
១៥៩ ហេតុបុណ្យជួយជូន ពុំឲ្យសោះសូន្យ រាស្ត្ររដ្ឋលង់ឡើយ
បានម្ចាស់ទ្រង់ធម៌ សម្ភាត្រាណត្រើយ យើងខ្ញុំបានស្បើយ
លះលែងទុក្ខា ។

កាលនោះពោធិ៍  សត្វសាងបារមី  ស្តែងស្តាប់វាចា
អស់រាជ្យបុរោហិត  ទូលពិតរច្នាះណា  សម្តេចរាជា
ស្តេចគង់ក្បែរមក្សាន្ត  ។

អស់អង្គសេនា  តែងរាជសារ  សាកសួរប្រធាន
នៅសព្វទិសទី  បុរីរាជស្ថាន  ឲ្យចូលមកឋាន
នាំអស់ស្នួយរ៉ៃ  ។

ភ្ញីមាសភ្ញីប្រាក់  ទ្រព្យធនសមស័ក្តិ  មកថ្វាយក្សត្រថ្លៃ
ឲ្យចូលមកជុំ  ជំនុំចងដៃ  ក្សត្រក្សាន្តផ្សៀស្នធ័យ
ឥស្សរសិរសី  ។

អាជ្ញាទៅដល់.  រួសរៀបខ្វាយខ្វល់  ចរចូលម្នាម្នី
នានាំស្នួយសារ  បណ្ណាការថ្មី  សាយសព្វទិសទី
ចូលមកជុំជិត  ។

២៦០ សេនាបតី  ជាឯកមន្ត្រី  រតនាពិពិធ
នាំស្តេចចេញក្រៅ  គាល់ហ្មៅម្ចលមិត្ត  ដូចដោយកំហិត
ច្បាប់ព្រះរាជសារ  ។

ស្តេចប្រទេសរាជ  សឹងតែកោតខ្លាច  ស្វែងបុណ្យសម្ភារ
សរសើរពោធិ៍  បារមីត្រកាល  យល់ជាអស្ចារ្យ
លើសលែងលោកិយ  ។

ទើបអស់ភ្នាក់ងារ  តែងព្រះរាជសារ  ប្រាមប្រះប៉មន្ត្រី
ជាក្សត្រអម្បរ  ឥស្សរសិរសី  ទ្រើសទ្រង់រាជ្យថ្មី
គ្រប់គ្រងសីមា  ។



រៀបរោងអភិសេក  ព្រះអង្គជាឯក  កំពូលលោកា
រណ្តាប់រួសរាន់  ឲ្យទាន់ពេលា  មន្ត្រីសេនា
មីរមែកប្រញាយ  ។

ធ្វើដោយកំណាន់  កំណត់គ្រប់គ្រាន់  រួសរៀបខ្វល់ខ្វាយ
ប្រដាប់មុខងារ  រាជាសព្វសាយ  ទាំងបាវទាំងនាយ
រួសរៀបស្រាប់ស្រេច  ។

២៦៥ ព្រាហ្មណ៍ព្រឹទ្ធហោរសាស្ត្រ  គន់គូរចេកមាស  យង់យល់រំពេច
ពេលាបើកបាន  បីស្ថានសម្រេច  ហោរដឹងសេចគ្រេច
ដោយក្បួនសៃយសាស្ត្រ  ។

ទើបអស់ព្រាហ្មណ៍ព្រឹទ្ធ  កវីបណ្ឌិត  សឹងគាល់ពេញពាស
ទៀងទូលដោយបូរ  គន់គូរចេកមាស  ដោយហោរផ្លុះឃ្លាស
ឃោគយាមយាយី  ។

ឫក្សពារពេលា  តាមដោយតម្រា  សឹងសម្រឹទ្ធិ
ឫក្សបើកបីស្ថាន  ពុំមានអ្វីៗ  ទោះទាំងរាសី
សុទ្ធសឹងតែជា  ។

កាលនោះព្រះបាទ  ព្រះបរមនាថ  ស្តេចចេញក្រឡា
គំនាល់រោងរ័តន៍  ពិចិត្រថ្លៃថ្លា  ស្ងំស្និទ្ធត្រៀបត្រា
ហែៗ ក្សត្រថ្លៃ  ។

អករ័យាយចាស់ទុំ  ចោមចារជិតជុំ  សឹងផណ្តាប់ស្បៀ
បួងបត់ចំណាង  តែងចងរបៃ  យូរថង់ដោយដៃ
ដើរជិតតាមគ្នា  ។

១៧០ ស្ដំស្ដិទ្ធសារពៃ អនេកក្រាស់ក្រៃ គង់គាល់ក្សត្រា
ស្ពាងស្អាតអស់រង្គ ផូរផង់កក្រ្កា កែក្រាយយាត្រា
ទន់ភ្លន់ល្អតល្វៃ ។

នាងខ្លះមុខមូល ផាត់ម្សៅត្រកូល ស្រស់ស្រៀបប្រិមប្រិយ
កាន់ផ្ចិតក្រដាស ពិលាបសោភី ស័ក្ដិសមកាយី
សម្រាប់បារមី ។

ព្រះពោធិសត្វ សាងសីលាព្រត ពន្លកជិនស្រី
កាលជាតិពីមុន ធ្វើបុណ្យក្រាស់ក្រៃ បុណ្យនោះឯងនៃ
តែងឲ្យសុខសាន្ដ ។

រៀបរោងរ័តន៍រម្យ កម្រាលព្រៃព្រំ បើកបាំងពិតាន
ដេរដាសសព្វសាយ រំកាយមាសមាន ស័ក្ដិសែងថ្កើងថ្កាន
រំយោលមាសម័យ ។

រាំងននបើកបាំង ខ្សែរត់រូតរាំង សន្និយានៃ
រំលេចផ្កាមាស ពេញពាសពេកក្រៃ រៀបរង់ក្សត្រថ្លៃ
បើកបាំងផុំផិត ។

១៧៥ អស់មុខមន្ត្រី សេនាបតី រាជវង្សបណ្ឌិត
បុរោហិតទាំងឡាយ រៀងរាយប្រកិត រាជគ្រូព្រាហ្មណ៍ព្រឹទ្ធ
អស់បរិពារផង ។

គង់គាល់ក្សត្រា លុះដល់ពេលា ស្ដេចចេញរោងទង
ភ្លេងភ្លាត់រងំ សូរសមស្គរទូង ស្រឡៃពាទ្យគង
សេពសមខ្លុយប៉ី ។



ត្រែស័ង្ខប្រគំ សូរស័ព្ទរងំ ទរទ្ទឹងគគៃ
ទើបព្រាហ្មណ៍បុរោហិត ចូលជិតពោធី សែកសូត្រស្ដុតី
ចម្រើនជយា ។

ក្សត្រសាក្យរាជ ទាំងរយឯងអាច ថ្វាយពរក្សត្រា
ចម្រើនព្រះស្រី វុឌ្ឍីចេស្ដា ចម្រើនជន្មា
ព្រះយសស័ក្ដិសែង ។

មន្ត្រីតូចធំ ក្រាបថ្វាយបង្គំ ថ្វាយជ័យជួយជែង
ចម្រើនពរថ្វាត់ ផាយផាត់កន្សែង មាលាគ្រវែង
ជូនជន្មក្សត្រក្សាន្ត ។

១៨០ រាស្ត្រក្នុងនគរ មូលមកវឹកវរ ពេញទាំងរាជស្ថាន
បណ្ដើរហូរហែ ឥតឯប្រមាណ នៅមុខព្រះលាន
ដេរដាសប្រកិត ។

ស្រែចថ្វាយសព្វសា- ធុការពរា ទ្រហឹងគ្រប់ពោត
ថាឱម្ចាស់យើង បុណ្យថ្កើងពេកក្កាត់ ដូចស្ថានសួគ៌ស្ថិត
កណ្ដាលអម្ពរ ។

រុងរឿងស័ក្ដិសែង ព្រះអង្គលើសលែង ក្សត្រសព្វនគរ
រាស្ត្រទាសជ្រែកជ្រៀត ប្របៀតមូលមក យង់យល់ភូធរ
អឹងកងទីទៃ ។

ភ្លេងភ្លាតរងំ ពេរាំម៉ូងគ្រំ រាំក្រវិស័យ
ជាគូស្នព្រ័ត្រ ត្លាញស្ទាត់វិលវៃ ខ្ពង់ខ្ពស់ពេកក្រៃ
រាំរយោងយាស ។

របាំមនោហ៍រា  រាំរេរកគ្នា  ហាក់ហោះអាកាស
របាំល្ខោន  ទន្ទោនពិលាស  បាត្តរេរ៉ាស
ដើរផិតតាមគ្នា  ។

១៨៦ ល្ខោនជាត្រី  រុងរឿងរស្មី  ល្អដូចទេវតា
គ្រចង់គ្រចះ  ស្រឡះអង្គា  កែក្រាយយាត្រា
បានបទលំនាំ  ។

មានទាំងកញ្ចែង  ធំពុកផ្សេង ៗ  រវាសរបាំ
សៀតក្រឹសដូចផ្កា  លីលាលលាំ  លលេទន្ទាំ
ស្អាញស្អុះលលះ  ។

មានទាំងចំបាប់  ប្រវាយចូលចាប់  ប្រឹងប្រែបោកប្រះ
សំឡក់សំឡឹង  ខេខឹងងងះ  ចាលចាញ់រហ័ស
មុខមិនរីករាយ  ។

មានល្បែងប្រដាល់  ចេះគន់កាត់ការ  ស្ទាក់ស្ទះកែកាយ
លោលោតទោមក៍  អ្នកអរវិលវាយ  ស្រែកស្រួលសប្បាយ
លោលោតទោទី  ។

មើលមានទាំងយួន  ហាត់បោយក្រដួន  វិលវាយគ្រវី
ងាគុនដារខ  យល់ល្អអស់ក្តី  ច្រៀងច្រូចសម្តី
សម្តែងភាសា  ។

១៩០ ចំពុកឯចិន  សុទ្ធសឹងតែប៉ិន  ហុកកៀននេះណា
សុទ្ធសឹងតែក្មេង  មែនទែនជានា  ប្រកាប់ច្បាំងគ្នា
ដោយបទនិយាយ  ។



រាស្រ្តផងសព្វស្រុក  ចូលមកគគុក  មើលមើលសប្បាយ
ដោយចិត្តចំណង់  មិនចង់លែងងាយ  ដែកចូលរពាយ
ប្របៀតពានពារ  ។

ប្រពាក់ប្រពូន  ខ្លះពទាំងកូន  បណ្តើរនាំគ្នា
ទាំងប្រុសទាំងស្រី  ទង្គិចប៉ះគ្នា  ណាស់ណាន់តៀបត្រា
អនេកក្រាស់ក្រៃ  ។

រាស្រ្តទាសក្នុងក្រៅ  ទោះទាំងផងព្រៅ  មិរមេកប្រស្រ័យ
មៀងមើលរបាំ  ឈរចាំហាលថ្ងៃ  ព្រាត់គ្នាទីទៃ
ជ្រែកជ្រៀតសព្វសាយ  ។

របាំមហោស្រព  ថ្លាថ្លៃផងគ្រប  នារីពាំថ្វាយ
ប្រដាប់គ្រប់គ្រឿង  រុងរឿងឆើតឆាយ  ល្អល្អះពណ្ណរាយ
ហាក់ទេពអប្សរ  ។

១៩៥ សុរសេព្ទភ្លេងផង  ទ្រហឹងអឹងកង  កក្រើកខ្ទរខ្ទារ
ឧឡារិកលាន់  ដោយបុណ្យភូធរ  រាស្រ្តរដ្ឋអឹងអរ
ស្រួលស្រើបសប្បាយ  ។

លុះការសម្រេច  ព្រះអង្គស្តេចស្តេច  ក្សេមក្សាន្តពណ្ណរាយ
សេពសោយរាជ្យរម្យ  ព្រះស្នំទាំងឡាយ  គង់គាល់រៀងរាយ
ជាផ្លូវប្រក្រតី  ។

អស់ក្សត្រស្រុកក្រៅ  ឡើងលព្រះចៅ  ទៅសព្វទិសទី
តំបន់រាជស្ថាន  បុរាណបុរី  ឯពង្សពោធិ
ថ្កើងយសស័ក្តា  ។

អស់មុខមន្ត្រី សេនាបតី ស្រាបណ៍ព្រាហ្មណ៍ព្រឹទ្ធា
រុងរឿងស័ក្តិសែង លើសលែងនានា ដោយតេជចេស្តា
ការម្យឫទ្ធី ។

## បទព្រហ្មគីត

១៨៤ នេះយើងនឹងថ្លាថ្លែង ចរចាចែងដំណើរពី
ស្តេចបានគ្រងបុរី សោយសម្បត្តិសម្បូរបុណ្យ ។
១៨៦ ព្រះអង្គគ្រងពល្យរ័ក្ស ថ្កើងអនិត្យអនេកលន់
និរអ្នកនឹងប៉ះប៉ុន ប្រៀបធៀបត្រឹមព្រះអង្គបាន ។
ទើបយើងបញ្ឈប់ស្លេះ នឹងសំណេះថ្លែងឯព្រាន
សន្ទូចទាំងពីរប្រាណ កាលរើសរាជកុមារនោះ ។
ព្រានទុកជាបុត្រភ្ញា ស្ងួនរក្សាពុំមានហោះ
ស្មើកូនកើតពីពោះ ពិតពុំឲ្យអាក់ហឫទ័យ ។
ព្រានទាំងពីរវង្គា ញាតិនឹងគ្នាពុំដទៃ
ជួបចូលចិត្តប្រុស្រ័យ សឹងរម្យរបុរោហិត ។
កុមារទាំងពីរពង្ស ពំនាក់អង្គនឹងព្រាហ្មណ៍ព្រឹទ្ធ
ពុំដឹងក្រុងសុភមិត្រ ជាបិតាឬមាតា ។
១៩០ ចេញចាកពីសម្បត្តិ ប្រាសព្រាយព្រាត់រាជបុត្រា
អង្វែងមកនាគ្រា គ្រប់ប្រាំឆ្នាំមកកន្លង ។
ហើយទើបរាជកុមារ ព្រានព្យាបាលមាសស្នេហ៍ស្នង
អ្នកពុំដឹងទំនង របស់ដំណើរអតីត ។



មានកាលថ្ងៃមួយនោះ
ហៃអ្នកមាសពុំពោ
អពុកនៅសព្វថ្ងៃ
ហានបាងឯងជាត្រើយ
អាពុកចាស់ហើយណា
អាពុកគិតប៉ុនប៉ង
១៩៥ ថ្វាយថ្វាត់មហាក្សត្រក្សាន្ត
ឲ្យបានគាល់លោកិយ
កុមារទាំងពីរស្តាប់
អ្នកឆ្លើយស្នងវែងថា
មានកាលថ្ងៃមួយណា
ព្រាននាំបុត្រទៅផ្ទង
ព្រានឱនអង្គប្រណម្យ
ទើបព្រានក្រាបទូលថា
យើងខ្ញុំពីរអង្គា
ថ្វាត់ថ្វាយព្រះចក្រី
២០០ ក្សិណនោះពុទ្ធង្កុល
ស្តេចត្រេកសោមនស្សា
ថាហៃព្រានព្រះស្តេង
បុត្រព្រានឯងឬអ្វី

ព្រានចំពោះឥណ្ឌឹងថា
ស្ងួនសម្លាញ់អាពុកអើយ ។
ចិត្តអាល័យបាណាស់ហើយ
គ្រាន់ពំនាក់អាពុកហោង ។
មានតែបាបុត្រស្ងួនគ្រង
នឹងយកបាបុត្រពិសី ។
ជាប្រធានពជបុរី
ប្រយោជន៍យកយសស័កា ។
របស់សាសព្វព្រានវាចា
តាមតែអ្នកអាពុកហោង ។
ពារពេលាល្អកន្លង
ដល់មន្ទីរមហាក្សត្រា ។
ថ្វាយបង្គំព្រះរាជា
បពិត្រក្សត្រាធិបតី ។
នាំបុត្រាពីរមកខ្ញី
ជាឥស្សរលើសិរសា ។
ស្តាប់ព្រានទូលថ្វាយក្សត្រា
បន្ទូលសួរសព្វសេចក្តី ។
ចូរថ្លាថ្លែងប្រាប់អញខ្មី
យល់ឆោមឆាយពន់ពេកក្តាត់ ។

អញធ្វល់នឹងព្រានថា  កូនព្រានណាម្ដេចមិនកាត់
អញឆ្ងល់មិនអស់ចិត្ត  ពូជពង្សព្រានជាបិតា ។
ទើបព្រានទូលរឹងថ្កាន  ថាសូមទានកូននេះណា
ប្រហែលទៅមាតា  ជាខ្ញុំស្រីព្រះអង្គហោង ។
ស្ដេចជឿពុំសង្កា  ទើបព្រានណាវិលទៅផ្គង
លំនៅដូចសព្វផង  តែងទៅស្ដួចជាអម្រែស់ ។
២០៩ ឯពង្សពោធិសត្វ  សោយសម្បត្តិបុណ្យខ្ពង់ខ្ពស់
ប្រកបនូវព្រះយស  យូរលុះឆ្នាំមួយទៀងទាត់ ។
កុមារពីរពិសាល  ធំពេញពាលរូបល្អក្កាត់
និត្យនៅនឹងមហាក្សត្រ  ពុំដែលឃ្លាតទិនមួយណា ។
ហេតុបាបបាំងក្សត្រក្សាន្ត  ពីបុរាណពងច្រើនគ្រា
នឹងឲ្យរងវេរា  ដរាបរៀងរាល់សព្វជាតិ ។
ស្ដេចភ្លាំងភ្លេចពូជព័ណ៌  ពិតពុំស្គាល់បុត្រឹងអាទិ
ស្ដេចយល់មានមារយាទ  ផ្គាប់បម្រើត្រូវព្រះទ័យ ។
ស្ដេចស្ដែងរែងរក្សា  ទ្រង់មេត្តាពន់ពេកក្រៃ
ហាក់បុត្របង្កើតនែះ  គឺមោះស្ដេចពិតពុំដឹង ។
២១០ ពុំជាក់ជាពជបុត្រ  ថ្លៃពិសុទ្ធពិសេសផ្សឹង
កាលព្រាត់នៅក្មេងសឹង  ពុំទាន់ដឹងដំណើរនៃ ។
ស្ដេចឲ្យជានាយមហាត  ពុំឃ្លាឃ្លាតពីក្សត្រថ្លៃ
កុមារពីរប្រពៃ  ពឹងសម្ភារព្រះបារមី ។



ព្រះបាទក្រុងសុភមិត្រ  ទ្រង់ទសពិធធម៌វិន័យ
រក្សាមុខមន្ត្រី  នូវព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតណា ។
ស្ដេចឲ្យទានទ្រព្យធន  ពុំជិនឆ្អន់ព្រះទយា
គ្រប់អស់អង្គសេនា  នូវអស់រាស្ត្រផងសព្វស្ថាន ។
ស្ដេចទ្រង់ព្រះសទ្ធា  សាងសាលាទុកឲ្យទាន
ចែកចាយទ្រព្យធនជាន  ជាប្រក្រតីសព្វទិវា ។
២១៩ រាស្ត្ររដ្ឋមីរមកមាន  យកព្រះទានមហាក្សត្រា
ចិញ្ចឹមបុត្រករិយា  បានបរិបូណ៌ស៊ីស្កប់ស្កល់ ។
រចាំពំនិយាយ  រាស្ត្រទាំងឡាយមករចល់
មើលមីរពេញបណ្ដល  ទើបឲ្យទានភោជនផង ។
នៅជោយទ្វារនគរ  និរន្តររៀងទៅហោង
ជាប្រក្រតីសព្វផង  ពុំដែលដាច់ទិនទិវា ។
យើងថ្វាថ្លែងស្រដី  ដំណើរពីពជបុត្រា
សូវេចម្លេះហើយណា  យើងបញ្ឈប់ទុកសិនហោង ។
ទើបយើងនឹងស្រដី  ដំណើរនិយាយទំនង
ឯក្សត្រីជាច្បង  នាងនៅនឹងនាយកេត្រា ។
២២០ តែងទល់ទុក្ខសោកសោះ  គិតស្រណោះបុត្រថ្លៃថ្លា
នូវព្រះរៀមរាជា  ប្រែប្រាសព្រាត់ទៅទីទៃ ។
នាងនាថតែងទួញទល់  ទុក្ខសោកសល់ពន់ពេកក្រៃ
សង្រេងតែងសង្រែ  ទល់ទុក្ខធ្ងន់ពន់កន្លង ។

នាយកេត្រាស្ងួរសារិន ពិតពុំហ៊ានក្ខចចិត្តចង
បានដឹងអស់ទំនង ជាដំណើរអតីតា ។
ទាំងនេះហេតុបុណ្យនាង បានសេពសាងស្នូមប្រាថ្នា
នឹងព្រះពង្សពុទ្ធា រៀងពីមុនមករាល់ជាតិ ។
ឯនាយកេត្រានោះ ចិត្តលប់ស្មោះពុំប្រមាទ
អាសូរនុះនាងនាថ រូបរក្សាស្មើជននី ។
២២៥ ពីដូចរើសនាងទៅ អ្នកសំពៅសុខសួស្តី
ចេញជួញសព្វបុរី សឹងយកនាងនាថទៅផង ។
វិកាលនោះឯងណា អ្នកកេត្រាចិត្តប៉ុនប៉ង
ចងចរចេញទៅផ្លូង ឯនគរគក្កសិលា ។
គិតស្រេចរូសរកទិញ អស់ទំនិញផ្ទុកកេត្រា
ទ្រព្យធនសឹងថ្លៃថ្លា ច្រើនអនេកពន់ពេកក្ដាក់ ។
លុះបានឫក្សពេលា បើកកេត្រាចេញទៅផ្ងាត់
អម្ទុងខែមួយក្ដាត់ ទៀងទើបបានដល់បុរី ។
បើកចូលចតជិតជាក់ ស្រេចទើបដាក់ផងក្ដោងថ្មី
ហើយស្រែកប្រាប់គ្នាគ្នី ឲ្យវាយឃ្មោះបោះយុថ្កា ។
៣០ -រៀបសែនដោយសៃយសាស្ត្រ ដុតក្រដាសទើបស្រោចស្រា
សំពះក្រាបបូជា លាបំណន់ស្រេចហើយនៃ ។
នាយកេត្រាខ្វល់ខ្វាយ រៀបគង្វាយសឹងៈប្រពៃ
ទ្រព្យទេសសឹងពម្លៃ គ្រប់បណ្ដាការស័ក្តិសម ។



តាមដោយច្បាប់កេត្រាធំ
ត្រកទាតែងបង្គាប់ ពួកទីទៃគ្រប់ទិសា ។
រៀបរួចដាក់ដោយដុំ នាំឡើងទៅកាលនោះណា
ទើបអស់អ្នកសំពៅ ក្រួញក្រាបទូលក្សត្រធិបតី ។
ដល់ដាក់អស់ភ័ស្ដុការ ឈ្មួញកេត្រាមកដល់ថ្មី
បពិត្រយើងខ្ញុំជា បរទេសមកថ្វាត់ថ្វាយ ។
យើងនាំទ្រព្យមកពី យើងខ្ញុំជាឈ្មួញស្រុកឆ្ងាយ
២៣៥ សូមស្ដេចទ្រង់មេត្តា ទើបមកម្ដងនេះឯងណា ។
ពុំដែលមកដល់អាយ ល្បីទូទ័រសព្វទិសា
ត្បិតឮម្ចាស់ទ្រង់ធម៌ ចូលមកជួញទាល់ទីអាយ ។
ទើបយើងទាំងអស់គ្នា ហៃអស់ពាណិជទាំងឡាយ
ស្ដេចស្ដាប់ហើយត្រាស់ថា លក់ដូរទិញកុំទើសទាល់ ។
ចូលជួញឲ្យសប្បាយ នាំទ្រព្យមកគ្រប់ព័ណ៌
អញអរនឹងនាយណា ទ្រព្យបរទេសមកចែកចាយ ។
សាយសព្វគ្រប់ប្រការ បង់សីមាមកដល់អាយ
បំណាច់នាយកេត្រា សព្វផ្សារផ្សាតាមចិត្តចៅ ។
លក់ដូរឲ្យសប្បាយ ថ្វាយបង្គំលាចុះទៅ
២៤០ នាយកេត្រាប្រណម្យ រៀបរួសរកជ្រកមាន់ទា ។
ជាស់តៀនអ្នកចុងភៅ ជុំគ្នាគ្នីស៊ីផឹកស្រា
ទិញភ័ស្ដុភោជ្យចំណី អ៊ូអឹងអាប់ស្មុរសព្ទសារិន ។
ស្រើបស្រួលនិយាយគ្នា

រួចហើយរៀបចែកចេញ　គិតលក់ទិញក្រែងនឹងមាន
ចំណេញចំណូលបាន　ថ្លៃពេកពន់ពេញចិន្តា ។
រើសរៀបរើទ្រព្យធន　ព្រែទេសគន់ខៀនកាសារ
លក់ដូរដោយប្រាថ្នា　អស់អ្នកផ្សារទទួលទិញ ។
ទ្រព្យធនទោះថោកថ្លៃ　សឹងដល់ដៃគ្រប់មកវិញ
លក់ដូរជាទំនិញ　ផ្ទុកភេត្រាជាប្រក្រតី ។
២៦៩ ថ្លឹងចេញថ្លឹងចូលស្រេច　គិតជាក្សាច់កត់បញ្ជី
បញ្ចូលសំពៅខ្មី　នាយនៃហ៊ិគិតខ្វាយខ្វល់ ។
ទៀងទាត់ផាត់បន្ថែ　ចូលជួញប្រែគិតឲ្យយល់
ពុំឲ្យមានសំណល់　ស្រេចហ្មត់ហ្មងដូចចិន្តា ។
ភេត្រាផ្ទុកពេញព្យេប　តែងប្រុងប្រៀបសព្វទិវា
ជួបជួនអស់គ្នីគ្នា　ចិត្តចង់ចេញចាកនគរ ។
គិតស្រេចនាយភេត្រា　នាំអស់ពាណិជចេញចរ
ឡើងទៅគាល់ភូធរ　ទៀងទើបទូលមហាក្សត្រា ។
សូមទានក្សត្រឧត្តម　អស់យើងខ្ញុំទាំងនេះណា
ឡើងមកក្រាបទូលលា　ព្រះអង្គជាម្ចាស់សិរសី ។
២៤០ ស្តេចស្តាប់នាយភេត្រា　ទើបព្រះមហាក្សត្រធិបតី
ស្តេចបើកបន្ទូលខ្មី　ទៅនឹងនាយភេត្រានោះ ។
ថាបៃពាណិជផង　យើងប៉ុនប៉ងចិត្តចំពោះ
ឈើផ្កាលពិតស្ម័គ្រស្មោះ　យើងរៀបល្បៀងអស់គ្នីគ្នា ។



ហើយយើងនឹងឲ្យរាំ　កាច់របាំស្រីកញ្ញា
ចូរនាយនូវអស់ពា-　ណិជទាំងឡាយនៅមើលរហោង ។
នាយភេត្រាប្រណម្យ　ថ្វាយបង្គំទូលរៀងស្នង
បពិត្រយើងខ្ញុំផង　សឹងរវល់នឹងលក់ទិញ ។
នឹងនៅលេងពុំបាន　ក្រែងខកខានលក់ទំនិញ
តែងផ្ទុកតែងកត់កាញ់　ផ្ទុកទៀបពេញចង់ចេញឆាប់ ។
២២៩ មួយសោតឯភេត្រា　កតគ្នីគ្នានៅប្រដាប់
ក្រែងខ្យល់បក់ទៅជាប់　ដល់បាក់បែកបង់ផ្ទុះផ្លាយ ។
ស្តេចស្តាប់នាយសំពៅ　ទូលព្រះចៅក្សត្រពណ្ណរាយ
ស្តេចថាអ្នកទាំងឡាយ　កុំព្រួយចិត្តក្រែងអសារ ។
សឹមអញប្រើទៅជួយ　ចាំកុំព្រួយខ្លាចថ្លោះការណ៍
បាត់បង់នោះទុកដារ　អញនឹងសងថ្លៃឲ្យជូន ។
ទើបនាយចងចិត្តចាំ　មើលរបាំភ្លេចទាំងខ្លួន
យល់ល្អពេញសមសួន　សុទ្ធសាធស្រីស្ងួតកញ្ញា ។
ទើបស្តេចត្រាស់ទៅថ្កាន　ប្រើកូនព្រានពីរអង្គា
ជានាយអស់នាំមហា-　តលិកទៅជួយចាំសំពៅ ។
២៦០ ឯអង្គពជកុមារ　ស្តាប់ឱង្ការពោធិចៅ
ស្តេចប្រើឲ្យចុះទៅ　មើលប្រយ័ត្នក្រែងថ្លោះធ្លោយ ។
កុមារក្រញក្រាបលា　នាំបរិពារទាំងប្រាំរយ
ចាំមើលក្រែងថ្លោះធ្លោយ　តែងដាស់តឿនប្រុងប្រយ័ត្ន ។

នាយមហាគលិកពីរពង្ស ចុះទៅគង់គយរង្គាត់
នៅក្បាលកេគ្រាថ្វាត់ មើលថែទាំចាំរក្សា ។
អស់មហាគលិកទាំងឡាយ ចាំរៀងរាយនៅនារា
ក្រវែលដោយទិសា ប្រុងប្រយ័ត្នក្នុងរាត្រី ។
កាលនោះឯជាយា ពជធីតាអគ្គមហេសី
នាងនៅជាប្រក្រតី នឹងពាណិជលើកេគ្រា ។
២៦៩ តែងគិតព្រះមិត្រមាស ត្បិតប្រែប្រាសព្រាត់ឃ្លាតឃ្លា
គិតបុត្រទាំងទ្វេហារ ក្រៀមក្រំកក្តែពុំស្រាកស្រាន្ត ។
ក្នុងរាត្រីនោះនៃ ក្សត្រីថ្លៃផ្ដំក្សេមក្សាន្ត
លក់លន់ពន់ប្រមាណ លុះអធ្រាត្រស្ងាត់ស្ងន្យសល់ ។
នាងផ្ដំក្នុងបាឡី សុខស្ងួស្តីស្ងួគ៏មណ្ឌល
បន្ទំទិព្វសព្វសល់ លើព្រះទែនទិព្វមាសម៉ៃយ ។
នាងយល់សប្ដិត្រកាល ជាអស្ចារ្យពន់ពេកក្រៃ
យល់ហាក់ដូចក្សត្រថ្លៃ គង់លើប្រាង្គប្រាសាទរ័តន៍ ។
យល់បុត្រទាំងទ្វេហារ ហាក់ដូចគ្រាមុនទៀងទាត់
ពុំយល់ជាព្រាយព្រាក់ គង់មូលមួយជាប្រក្រតី ។
២៧០ យល់ដូចបុរិសា ពីអង្គាមកទាល់ទី
ទឹមទៀបព្រះចក្រី កាន់យកផ្កាឈូកសស្អាត ។
ទាំងពីរវិសេសសល់ ដាក់តម្កល់ថ្វាយព្រះបាទ
ព្រះពោធិវង្សជាតិ ចាប់យកផ្កាឈូកមកខ្មី ។



ហុចឲ្យនាងជាយា ដល់ហត្ថាវក្សត្រី
ស្រេចនាងទទួលពី ព្រះវៀមហើយសៀតតាមា ។
ទាំងសងខាងបរ រុះកេសរលើឱរា
នាងតើនចាកត្រឡា បន្ទំទិព្វក្សត្រីថ្លៃ ។
នាងទ្រង់ព្រះចិន្តា ពិចារណាអធ្យាស្រ័យ
ល្បែងដោយប្រាជ្ញាញៃយ្យ នាងជ្រួតជ្រាបសព្វប្រការ ។
២៧៥ យល់ជាក់ជានឹងបាន ឮពត៌មានពីកុមារ
នឹងព្រះវៀមពជា នឹងបានជួបពុំឃ្លាឃ្លាត ។
នាងដឹងដោយសប្តិជាក់ កាលនាងភ្ញាក់នាអធ្រាត្រ
នាងទូញទៅព្រះបាទ ឱព្រះវៀមជាស្វាមី ។
ស្តេចប្រាសពីទ្រង់ប្អូន រសោរសូន្យទៅទូរទី
នៃទើបតែរាត្រី នោះបានយល់ព្រះច្បាស់ច្បង ។
ប្អូនយល់ជាក់សព្វគ្រប់ ប្អូនវែងថប់ ៗ កន្លង
បាត់ពុំយល់ព្រះបង ប្អូនស្រណោះអាឡោះលន់ ។
ខ្ញុំយល់អម្បាញ់មិញ ក៏ប្អូនពេញចិត្តពេកពន់
ប្អូនភ្ញាក់ឡើងរកគន់ គិតព្រះបាទព្រះបងបាត់ ។
២៧០ ឱប្អូនសោកខ្លោចផ្សា ឈឺឱរាក្តៅប្រមាត់
ពុងពោះដូចគេកាត់ ឈឺតានតឹងស្មើរដាច់ខ្យល់ ។
នាងទូញទាំងអធ្រាត្រ នឹងរវនាថរកទសពល
ហើយនាងនាថនិម៌ល ទូញទៅបុត្រទាំងពីរពង្ស ។

ឱកូនស្ងួនសម្លាញ់ បាប្រាសចេញបោះម្តាយបង់
ជាអង្វែងយូរលង់ លុះឥឡូវនេះឯងណា ។
ម្តាយបានយល់សប្តិជាក់ ឃើញមុខអ្នកមាសពុំងា
ម្តាយភ្ញាក់ឡើងស្រវា រកអ្នកមាសពុំយល់ឡើយ ។
ម្តាយរវៃងឈឺក្រៃក្រៃ ម្តាយអាល័យបាពុំស្បើយ
ឱអ្នកមាសម្តាយអើយ ម្តាយទល់ទុក្ខពន់ពេកក្តាត់ ។
២៨៥ ទ្រូងម្តាយស្មើរនឹងបែក ដូចគេហែកហ្វូរប្រមាត់
ពុងពោះដូចគេកាត់ ដូចគេកូរឈើខ្លោចផ្សា ។
នាងសោកព្រះរាជបុត្រ ញ័ររន្ធត់អស់អង្គា
ជលនេត្រទាំងទ្វេហារ ស្រក់សស្រោកឥតស្រាកស្រាន្ត ។
នាងទួញដល់ដាស់ទំ ឱរាក្រំក្រៃប្រមាណ
សោយសោកយំប្រះប្រាណ ននៀលនៅបន្ទំទី ។
២៨៨ ឯអស់លោកភេត្រា ពុំដឹងជានាងទេវី
ទួញយំក្នុងរាត្រី ដេកលក់លន់ពន់ពេកក្តាត់ ។

បទភាគគតិ

១៩៩ កាលនោះកុមារ ពីរពង្សអង្គា រង្គុយនៅនិត្យ
នាក្នុងរាត្រី ទៀបទីឋានបិត នាងនារីរ័តន៍
នៅក្បាលភេត្រា ។
២០០ ឯចៅជ័យទត្ត ព្រះអនុជរ័តន៍ អង្គុយខាងគ្នា
ងងុយងងឹត ធ្មេចបិទនេត្រា ស្ទន្យស្រុងនិទ្រា
ធ្មេសទ្វេសុបសោ ។



ឯចៅជ័យសែន នរនាថនរេន្ទ្រ អង្គុយនិត្យនៅ
ពុំមានភ្លឹកភ្លាត់ ប្រយ័ត្នសំពៅ ខ្លាចក្រែងសាត់ទៅ
ព្រួយប្រាណចិន្តា ។
លុះឮសូរសៀង រហាក់រហៀង ពាក្យពេចន៍ភាសា
សម្តីសម្លែង ថ្លាថ្លែងចរចា ទួញទៅបុត្រា
រកពជស្វាមី ។
អ្នកគិតកាន់កូច ស្វែងស្តាប់ហាក់ដូច ជាក់ជានារី
អ្នកគិតវែងឆ្ងល់ ពុំយល់សេចក្តី រះរំពឹងពី
មាតាបិតា ។
សង្វេគឋាឫទ័យ បារម្ភសព្វថ្ងៃ នឹកក្នុងចន្តា
អង្គីក្តីសល់ ទើបយល់ក្នុងគ្រា នេះម្តងយល់ជា
អស្ចារ្យពេកក្តាត់ ។
២០៩ ពីមុនមិនដែល ឥឡូវប្រហែល ឮសព្ទដូចមាត់
សម្តីសម្លែង ថ្លាថ្លែងកាលព្រាត់ កាលប្រាសបុត្របាត់
បោះបង់ឃ្លាតឆ្ងាយ ។
ព្រះរៀមភូធរ អ្នកយកព្រះករ ករកេះកកាយ
អង្រន់អង្រួន ថាស្ងួនបងអាយ ម្តេចអ្នកសប្បាយ
លន់លក់ព្រងើយ ។
ឱស្ងួនសម្លាញ់ កាលយើងចាកចេញ អង្វែងយូរហើយ
ពីព្រះមាតា បិតាគ្រាណត្រើយ ឱអ្នកប្អូនអើយ
យើងមហាកំព្រា ។

អនុជស្តេចស្តាប់ ព្រះវៀមប្រាយប្រាប់ ដំណើរនោះណា
អ្នកនឹកឆ្ងល់ឆ្ងាយ ស្ទើរធ្លាយឱរា រូតរឹតចិន្តា
តបដណ្តឹងខ្ទី ។

បោអ្នកបងអើយ ដំណើរដើមឡើយ អស់អាថ៌សេចក្តី
ចូរអ្នកប្រាយប្រាប់ សណ្តាប់សម្តី សម្តែងពាក្យពី
មុនមកនឹងស្តាប់ ។

២១០ ព្រះវៀមឆ្លាស់ឆ្លើយ ថាបោប្អូនអើយ បងមិនហ៊ានប្រាប់
ពាក្យនេះមិនងាយ កំឈឃ្មុំសាសព្វ យើងវែងអគ័ព្វ
ក្រែងកើតអប្រិយ ។

ថាឱប្អូនអើយ បងប្រាប់អ្នកហើយ កុំអ្នកស្រដី
ខ្លាចក្រែងឮលេច ពាក្យពេចន៍អ្វីៗ យើងសុខសេចក្តី
ឥតបីពឹងពាក់ ។

ចូរប្អូនស្ងួនភ្ជា អ្នកយកព្រះកាណ៌ ស្តែងស្តាប់ឲ្យជាក់
បងនឹងប្រាប់ប្រាយ ចែងចាយឲ្យអ្នក ដឹងអាថ៌ផ្សេងជាក់
ណាប្អូនពិសី ។

ថាហៃប្អូនអើយ បងមិនលាក់ឡើយ អស់អាថ៌អំពី
មាតាបិតា ថ្លៃថ្លាធិបតី និត្យនៅបុរី
ចម្បាកនគរ ។

សោយរាជសម្បត្តិ ឥស្សរាស្ត្ររដ្ឋ ពលព្រឹន្ទរឹករវ
យើងពីរពិស្សុទ្ធ ជាបុត្រភ្ញូធរ កើតឯកឧទរ
មួលមួយជននី ។



២១៩ ព្រះវរបិតា មានអនុជា គ្រប់គ្រងបុរី
ជាតិជាឧបរាជ ចិត្តកាចក្តិរ៍យ ទ្រឹស្តទ្រុស្តអប្រិយ
បៀតបៀនបិណ្ឌា ។

ចិត្តចង់ប្រមាទ ប៉ុនប៉ងពិឃាត ព្រះវរបិតា
ផ្តុំមុខមន្ត្រី សេនីយ៍សេនា ពលពាលត្រៀបត្រា
អនេកក្រាស់ក្រៃ ។

ដល់ថែករង្វាន់ មាសប្រាក់គ្រប់គ្រាន់ ដោយត្អូញទៃ
ប្រដាប់គ្រឿងសឹក ពន្លឹកនិរភ័យ ចង់បានថ្មីដៃ
យករាជសម្បត្តិ ។

កាលនោះអមាត្យ ជំនិតព្រះបាទ មួយមានគុណភ្លាត់
លួចឡើងមកទូល ដោយបូរទៀងទាត់ ទើបព្រះមហាក្សត្រ
ព្រះវរបិតា ។

មិនមានចិត្តចង ប្រកួតប្រឡង នឹងអនុជា
នាំយើងចៀសចាក លះលាកសីមា នូវព្រះមាតា
ទាំងយប់រាត្រី ។

២២០ ដើរដួចដល់ស្ទឹង ងងឹតសូន្យឈឹង ទើបព្រះជននី
អ្នកយកសំពត់ បត់ដាក់នៅដី ផ្តេកដាក់ទូលទី
ក្រោមដើមព្រឹក្ស ។

ទៀតទាំងយប់ជ្រៅ អ្នកផ្តេកបំបៅ អ្នកប្អូនពុំងា
ហើយអ្នកល្អងលោម ផ្ទាក់ថ្នមប្រវា ថើបថៃសិរសា
អង្អែលឱបអង្គ ។